

NSW GOVERNMENT

# ការចាក់វ៉ាក់សាំងមេនីញហ្គោខូខល ACWY សម្រាប់សិស្សថ្នាក់ទី10

## ព័ត៌មានសំខាន់ ឆ្នាំ2025

## ការយល់ព្រមតាមអនឡាញមានសម្រាប់ការចាក់វ៉ាក់សាំងនៅសាលារៀន

ឪពុកម្ដាយ និងអាណាព្យាបាលអាចផ្ដល់ការយល់ព្រមតាមអនឡាញ សម្រាប់ការចាក់វ៉ាក់សាំងជាប្រចាំរបស់កូនពួកគេ ពេលណាពួកគេរៀននៅថ្នាក់ទី10។

**អ្នកនឹងត្រូវការ៖**

1. ព័ត៌មានលម្អិតបើកចូលសេវាកម្ម NSW របស់អ្នក
2. លេខប័ណ្ណ Medicare របស់អ្នក និងកូនរបស់អ្នក (ប្រសិនបើអ្នកទាំងពីរមានប័ណ្ណមួយ)
3. ព័ត៌មានលម្អិតអំពីសាលាមធ្យសិក្សាដែលកូនរបស់អ្នកចូលរៀននៅឆ្នាំ2025។

សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងកម្មវិធីចាក់វ៉ាក់សាំងថ្នាក់ទី7 នៅសាលារៀនរដ្ឋ NSW សូមចូលទៅកាន់គេហទំព័រ health.nsw.gov.au/schoolvaccination

ដើម្បីផ្ដល់ការយល់ព្រមតាមអនឡាញ សូមចូលទៅកាន់គេហទំព័រ https://engage.health.nsw.gov.au/engage

**ព័ត៌មានបន្ថែម៖**

# Translations in 27 languages
# Visit **www.health.nsw.gov.au/schooltranslations**

العربية (Arabic)

لقراءة هذه المعلومات الهامة بلغتك، تفقّد الموقع الإلكتروني المبيّن أعلاه.

বাংলা (Bangla)

এই গুরুত্বপূর্ণ তথ্য আপনার নিজের ভাষায় পড়তে, উপরের ওয়েবসাইটটি দেখুন।

မြန်မာ (Burmese)

ဤအရေးကြီးသော သိကောင်းစရာအချက်အလက်များကို သင့်ဘာသာစကားဖြင့် ဖတ်ရှုရန်အတွက်၊ အထက်ပါ ဝက်ဘ်ဆိုက်သို့ ကြည့်ပါ။

中文 (Chinese)

如欲閱讀這份重要資料的中文本，請瀏覽以上網頁。

دری (Dari)

برای خواندن این معلومات مهم به زبان خود تان، به ویب سایت فوق مراجعه کنید.

Thuɔŋjäŋ (Dinka)

Të bïn lëk thekiic kän kueen në thoŋ du, kɛ̈nyë/lɔr ë webthiat tɔ̈ nhial.

فارسی (Farsi)

برای خواندن این اطلاعات مهم به زبان خودتان، به وب سایت بالا مراجعه کنید.

Français (French)

Pour lire ces informations importantes dans votre langue, visitez le site Web ci-dessus.

हिंदी (Hindi)

इस महत्त्वपूर्ण जानकारी को अपनी भाषा में पढ़ने के लिए उपरोक्त वेबसाइट पर जाएँ।

Bahasa Indonesia (Indonesian)

Untuk membaca informasi penting ini dalam bahasa Anda, silakan kunjungi situs web (website) di atas.

日本語 (Japanese)

この重要な情報を日本語でお読みになりたい方は、上記ウェブサイトをご覧ください。

ကညီကျိာ် (Karen)

လၢနကဖးတၢ်ဂ့ၢ်တၢ်ကျိၤအကါဒိၣ်တမံၤအံၤလၢနကျိာ် ဒၣ်နဲအဂီၢ်. လဲၤဆူပှာ်ယဲၤသန့အိၣ်လၢထးန့ၣ်တက့ၢ်.

ខ្មែរ (Khmer)

ដើម្បីអានព័ត៌មានដ៏សំខាន់នេះជាភាសារបស់អ្នក សូមបើកចូលវ៉ិបសាយខាងលើនេះ។

한국어 (Korean)

본 주요 정보를 한국어로 보시려면, 위의 웹사이트를 방문하시기 바랍니다.

ລາວ (Lao)

ເພື່ອອ່ານຂໍ້ມູນອັນສຳຄັນນີ້ ເປັນພາສາຂອງທ່ານ ຈົ່ງເຂົ້າເບິ່ງເວັບໄຊຕ໌ທີ່ຢູ່ຂ້າງເທິງ.

नेपाली (Nepali)

यो महत्वपूर्ण जानकारी तपाईको आफ्नै भाषामा पढ्नको लागि, माथि उल्लेखित वेबसाईट हेर्नुहोस्।

Português (Portuguese)

Para ler esta informação importante na sua língua, visite o sítio web mostrado no topo da página.

ਪੰਜਾਬੀ (Punjabi)

ਇਸ ਮੱਹਤਵਪੂਰਨ ਜਾਣਕਾਰੀ ਨੂੰ ਆਪਣੀ ਭਾਸ਼ਾ ਵਿਚ ਪੜ੍ਹਨ ਲਈ ਉਪਰੋਕਤ ਵੈਬਸਾਈਟ ਤੇ ਜਾਓ।

Русский язык (Russian)

Прочитать эту важную информацию на своем родном языке вы можете, посетив указанный выше сайт.

Fa'a-Samoa (Samoan)

Mo le faitauina o nei faamatalaga taua tele i lau lava gagana, asiasi i le upega tafa'ilagi (website) pei ona ta'ua i luga.

Español (Spanish)

Para leer esta importante información en español, recurra a la página web indicada arriba.

தமிழ் (Tamil)

இம் முக்கிய தகவலை உங்கள் மொழியில் வாசிக்க மேலுள்ள வலைத்தளத்திற்குச் செல்க.

ไทย (Thai)

อ่านข้อมูลสำคัญนี้เป็นภาษาไทย ไปที่เว็บไซต์ที่อยู่ด้านบนนี้

Lea Faka-Tonga (Tongan)

Ke lau 'a e fakamatala mahu'ingá ni 'i ho'o lea tu'ufonuá, 'a'ahi ki he uepisaiti 'i 'olungá.

Türkçe (Turkish)

Bu önemli bilgiyi kendi dilinizde okumak için yukarıdaki internet sitesine giriniz.

Українська мова (Ukrainian)

Щоб ознайомитися з цією важливою інформацією рідною мовою, відвідайте вищевказаний сайт.

Tiếng Việt (Vietnamese)

Muốn đọc thông tin quan trọng này bằng ngôn ngữ của quý vị hãy thăm trang website ghi trên.

October 2024 © NSW Health. SHPN (HPNSW) 240750.

# ការចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY

Meningococcal ACWY vaccination

## សន្លឹកព័ត៌មានសម្រាប់ឪពុកម្ដាយ

NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) ផ្ដល់ជូនវ៉ាក់សាំងដែលបានណែនាំសម្រាប់មនុស្សជំទង់ដោយក្រុមប្រឹក្សា¥ស្រាវជ្រាវផ្នែកសុខភាព នឹងវេជ្ជសាស្ត្រជាតិក្នុងកម្មវិធីចាក់វ៉ាក់សាំងនៅតាមសាលារៀន។ ត្រូវផ្ដល់ការយល់ព្រមដែលបានចុះហត្ថលេខាដោយឪពុកម្ដាយ/អាណាព្យាបាល។

វិធានការបន្ទាប់របស់អ្នក

- សូមអានសន្លឹកព័ត៌មាននេះដោយប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងនឹងមេនីញហ្គោខូខល ACWY សូមផ្ដល់ការយល់ព្រមរបស់អ្នកតាមអនឡាញ ឬស្នើសុំទម្រង់បែបបទយល់ព្រមជាសណ្ឋានក្រដាសពីសាលារៀនរបស់អ្នក។
- ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺមេនីញហ្គោខូខល ACWY ទេ សូមកុំផ្ដល់ការយល់ព្រម។

### សំណួរ. តើខ្ញុំផ្ដល់ការយល់ព្រមចំពោះចាក់វ៉ាក់សាំងនៅសាលារៀនដោយរបៀបណា?

ដើម្បីផ្ដល់ការយល់ព្រមតាមអនឡាញ អ្នកនឹងត្រូវការ៖

1. ព័ត៌មានលម្អិតបើកចូលសេវាកម្ម NSW របស់អ្នក
2. លេខប័ណ្ណ Medicare របស់អ្នក និងកូនរបស់អ្នក (ប្រសិនបើអ្នកទាំងពីរមានប័ណ្ណមួយ)

- ប្រសិនបើអ្នក ឬកូនរបស់អ្នកមិនមានប័ណ្ណ Medicare ទេ អ្នកនៅតែអាចផ្ដល់ការយល់ព្រមដដែល ដោយស្នើសុំទម្រង់បែបបទជាសណ្ឋានក្រដាស (មានតាមការស្នើសុំពីសាលារៀន)។

### សំណួរ. តើខ្ញុំអាចដកចេញការយល់ព្រមបានទេ?

ឪពុកម្ដាយអាចដកចេញការយល់ព្រមនៅពេលណាក៏បាន  មុនពេលការចាក់វ៉ាក់សាំងកើតឡើង។

នៅកន្លែងណាដែលការយល់ព្រមត្រូវបានផ្ដល់ឱ្យតាមអនឡាញ សូមបើកចូលវិបផតថលការយល់ព្រមតាមអនឡាញ NSW Health ដែលមានសុវត្ថិភាព ហើយធ្វើតាមការម្លឹកនានាដើម្បីដកចេញការយល់ព្រម។

នៅកន្លែងណាដែលការយល់ព្រមត្រូវបានផ្ដល់ឱ្យនៅលើទម្រង់បែបបទជាសណ្ឋានក្រដាស សូមសរសេរ ឬទូរសព្ទទៅសាលារៀន ដើម្បីផ្ដល់ឈ្មោះសិស្ស ថ្នាក់រៀន និងវ៉ាក់សាំងទាំងនោះដែលពាក់ព័ន្ធការយល់ព្រមដើម្បីដកចេញ។

### សំណួរ. តើអ្វីជាជំងឺមេនីញហ្គោខូខល?

ជំងឺមេនីញហ្គោខូខល គឺជំងឺឆ្លងធ្ងន់ធ្ងរមួយ ប៉ុន្តែកម្រកើតមាន ដែលធម្មតាបណ្ដាលឱ្យកើតរោគរលាកស្រោមខួរ (រលាកភ្នាសខាងក្នុងខួរក្បាល និងខួរឆ្អឹងខ្នង) និង / ឬរោគពិសឈាម (ការពុលឈាម)។

រោគសញ្ញានៃជំងឺមេនីញហ្គោខូខល ប្រហែលជាគ្មានភាពជាក់លាក់ទេ ប៉ុន្តែអាចមានរួមទាំងការកើតគ្រុនក្ដៅភ្លាមៗ ឈឺក្បាល រឹងកញ្ចឹងក ឈឺសន្លាក់ឆ្អឹង ស្នាមកន្ទួលជាំ ឬស្នាមជាំ មិនចូលចិត្តពន្លឺខ្លាំង ចង្អោរ និងក្អួត។

រហូតដល់ទៅ១០ភាគរយនៃការឆ្លងមេរោគមេនីញហ្គោខូខល ប៉ះពាល់ដល់ជីវិត ទោះបីជាបានព្យាបាលជាមួយថ្នាំផ្សះសមស្របក្ដី ហើយអ្នកជំងឺដែលនៅរស់រានមានជីវិត អាចមានជាប់នូវផលវិបាករយៈពេលយូរ។

### សំណួរ. តើជំងឺមេនីញហ្គោខូខល ឆ្លងរាលដាលដោយរបៀបណា?

បាក់តេរីមេនីញហ្គោខូខល ឆ្លងពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀតតាមរយៈទឹកមាត់ពីទីជំរៅនៃច្រមុះ និងបំពង់ក។ ជាទូទៅ ការឆ្លងនេះតម្រូវឱ្យមានការប៉ះពាល់ជិតស្និទ្ធ និងយូរ ជាមួយអ្នកផ្ទុកបាក់តេរីដែលជាគ្មានជំងឺអ្វីសោះឡើយ។ ឧទាហរណ៍នៃ 'ការប៉ះពាល់ជិតស្និទ្ធ និងយូរ' គឺការរស់នៅក្នុងផ្ទះជាមួយគ្នា ឬការថើបស្និទ្ធស្នាលខ្លាំង (ថើបជញ្ជក់មាត់)។ បាក់តេរីមេនីញហ្គោខូខល មិនឆ្លងរាលដាលដោយងាយស្រួលពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀតទេ ហើយបាក់តេរីនេះក៏មិនរស់រានបានល្អឡើយ នៅខាងក្រៅរាងកាយមនុស្ស។

### សំណួរ. តើវ៉ាក់សាំងដំណើរការដោយរបៀបណា?

វ៉ាក់សាំងដំណើរការដោយធ្វើឱ្យប្រព័ន្ធភាពស៊ាំ ប្រយុទ្ធប្រឆាំងនឹងមេរោគជាក់លាក់មួយចំនួន។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់ជាមួយមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់គេអាចឆ្លើយតបបានកាន់តែប្រសិទ្ធិភាពដោយបង្ការកុំឱ្យជំងឺវិវត្ត ឬកាត់បន្ថយភាពធ្ងន់ធ្ងររបស់វាបានយ៉ាងច្រើន។

### សំណួរ. តើវ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល មានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY រួមគ្នាតែមួយលើក មានប្រសិទ្ធិភាពខ្លាំងណាស់ ក្នុងការផ្ដល់នូវកិច្ចការពារប្រឆាំងនឹងប្រភេទទាំងបួននេះនៃជំងឺមេនីញហ្គោខូខល។ វ៉ាក់សាំងនេះមិនអាចការពារប្រឆាំងនឹងជំងឺមេនីញហ្គោខូខលបង្កឡើងដោយប្រភេទ B ឡើយ។

## សំណួរ. តើអ្នកណាគួរចាក់វ៉ាក់សាំង?

សិស្សទាំងអស់រៀននៅថ្នាក់ទី១០ នៅសាលាមធ្យមសិក្សា និងសិស្សទាំងឡាយដែលមានអាយុលើសពី ១៥-១៩ឆ្នាំ ដែលរៀននៅមជ្ឈមណ្ឌលបង្រៀនភាសាអង់គ្លេសល្អិតល្អន់ គួរតែចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ក្រុមសេរ៉ូ A, C, W និង Y។

## សំណួរ. តើអ្នកណាខ្លះមិនគួរចាក់វ៉ាក់សាំង?

មិនគួរចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY ឱ្យមនុស្សដែល៖

- មាន ឬអាចមានផ្ទៃពោះ
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល មួយដូសពីលើកមុន
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងសារធាតុផ្សំបន្ថែមណាមួយ

មនុស្សដែលមានភាពស្រៀវយ៉ាងខ្លាំង ទៅនឹងវ៉ាក់សាំងការពាជំងឺខាន់ស្លាក់ ក៏មិនគួរចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY ឡើយ។

## សំណួរ. តើអ្វីជាប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី (anaphylaxis)?

អាណាហ្វីឡាក់ស៊ី គឺជាប្រតិកម្មទាស់នឹងសារធាតុយ៉ាងធ្ងន់ធ្ងរដែលអាចនាំឱ្យសន្លប់ពុំដឹងខ្លួន និងស្លាប់បាត់បង់ជីវិតទៀតផង ប្រសិនបើពុំបានព្យាបាលជាបន្ទាន់ទេ។

ការនេះកើតឡើងដោយកម្របំផុតបន្ទាប់ពីការចាក់វ៉ាក់សាំងណាមួយ។ គិលានុបដ្ឋាកចាក់វ៉ាក់សាំងនៅតាមសាលារៀន មានការហ្វឹកហ្វឺនយ៉ាងពេញលេញក្នុងការព្យាបាលប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី។

## សំណួរ. តើកូនរបស់ខ្ញុំមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY រួចរាល់ហើយទេឬ? តើវាមានសុវត្ថិភាពក្នុងការចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY ទេ?

វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY បានដាក់បញ្ចូលនៅក្នុងកម្មវិធីជាតិលើការចាក់ថ្នាំបង្ការរោគ សម្រាប់កុមារអាយុ១២ខែចាប់តាំងពីឆ្នាំ២០១៨មកម្លេះ។ កូនរបស់អ្នកប្រហែលជាបានចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល C កាលពីលើកមុន ដែលការពារប្រឆាំងទល់នឹងជំងឺមេនីញហ្គោខូខល C តែប៉ុណ្ណោះ។

វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY នេះ នឹងផ្តល់ដូសជំរុញមួយលើកប្រឆាំងនឹងជំងឺមេនីញហ្គោខូខល C ក៏ដូចជាការពារប្រឆាំងទល់ប្រភេទ A, W និង Y ផងដែរ។

ចំនួនសិស្សដ៏តិចដែលមានស្ថានភាពរោគជាក់លាក់ (ដូចជាគ្មានសរីរៈអណ្តើក ឬកង្វះភាពស៊ាំ) ប្រហែលជាបានចាក់វ៉ាក់សាំងនេះពីលើកមុនរួចហើយ។ ប្រសិនបើដូច្នេះមែន សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតព្យាបាលរោគទូទៅ ឬគ្រូពេទ្យឯកទេសរបស់អ្នក ប្រសិនបើកូនរបស់អ្នកដល់ពេលកំណត់ចាក់ដូសជំរុញ។

## សំណួរ តើអ្វីជាការបញ្ជាក់ផ្សេងទៀតសម្រាប់វ៉ាក់សាំងនេះ?

វ៉ាក់សាំងនេះក៏ត្រូវបានណែនាំផងដែរ សម្រាប់មនុស្សដែលមានផែនការធ្វើដំណើរទៅកាន់បណ្តាប្រទេសពាក់ព័ន្ធនឹងហានិភ័យខ្ពស់ នៃការរងប៉ះពាល់នឹងជំងឺមេនីញហ្គោខូខល រួមមានធម្មយាត្រា Hajj។ វ៉ាក់សាំងក៏ត្រូវបានណែនាំផងដែរសម្រាប់មុខរបរជាក់លាក់នានា ដូចជាបុគ្គលិកមន្ទីរពិសោធន៍មីក្រូជីវសាស្ត្រ និងសម្រាប់មនុស្សមានស្ថានភាពរោគជាក់លាក់ទាំងឡាយដូចជាអ្នកដែលសើរាង្គអណ្តើករបស់ខ្លួនមិនដំណើរការ។

## សំណួរ. តើវ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY មានសារធាតុផ្សំបន្ថែមអ្វីខ្លះ?

វ៉ាក់សាំងអាចមានផ្ទុកនូវសារធាតុ សូដ្យូមក្លរួ, សូដ្យូមអាសេតាត និងទឹកសម្រាប់ចាក់។ សារធាតុផ្សំបន្ថែមក្នុងបរិមាណយ៉ាងតិចបំផុតត្រូវបានដាក់បញ្ចូល ដើម្បីជួយឱ្យវ៉ាក់សាំងបំពេញមុខការរបស់វា ឬជួយកុំឱ្យវាខូច។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងដែលប្រើប្រាស់នៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយត្រូវតែឆ្លងកាត់ការធ្វើតេស្តសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលត្រូវបានអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ លើសពីនេះទៀត TGA តាមដានសុវត្ថិភាពនៃវ៉ាក់សាំងនៅពេលកំពុងត្រូវបានប្រើប្រាស់។

## សំណួរ. តើការចាក់វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY មានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាទូទៅមិនធ្ងន់ធ្ងរទេ ហើយតាមធម្មតាទាក់ទិននឹងការកើតមានជំងឺគ្រុនក្តៅ ឈឺក្បាល វិលមុខ ឬការឈឺចាប់ និងហើមប៉ោងនៅកន្លែងចាក់ថ្នាំ។ ប្រតិកម្មនៅកន្លែងចាក់ថ្នាំ ជាទូទៅនឹងជាឡើងវិញក្នុងរយៈពេល២-៣ ថ្ងៃ។ ផលប៉ះពាល់បន្ទាប់បន្សំធ្ងន់ធ្ងរកម្រឃើញមានណាស់។

ព័ត៌មានបន្ថែមអំពីផលប៉ះពាល់បន្ទាប់បន្សំ អាចរកបាននៅក្នុងព័ត៌មានផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នកប្រើប្រាស់ (CMI) សម្រាប់វ៉ាក់សាំង ដែលអាចរកបានពីគេហទំព័រ www.health.nsw.gov.au/schoolvaccination.

ឪពុកម្តាយដែលព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំបន្ទាប់ពីការចាក់វ៉ាក់សាំង គួរទាក់ទងមកវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់ពួកគេ ដែលពេលនោះវេជ្ជបណ្ឌិតគួរធ្វើរបាយការណ៍ទៅអង្គភាពសុខភាពសាធារណៈផងដែរ។

## សំណួរ. តើគួរចាក់វ៉ាក់សាំងដល់សិស្សស្រីដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះទេ?

ទេ។ សិស្សស្រីណាដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះ ពុំគួរចាក់វ៉ាក់សាំងទេ។ នៅថ្ងៃចាក់ថ្នាំ គិលានុបដ្ឋាកផ្នែកចាក់វ៉ាក់សាំងនឹងសួរសិស្សស្រីទាំងឡាយប្រសិនបើគេមាន ឬអាចមានផ្ទៃពោះ។ ប្រសិនបើសិស្សឆ្លើយទៅនឹងសំណួរនេះថាមាន នោះពុំត្រូវបានគេចាក់វ៉ាក់សាំងឱ្យឡើយ។ សិស្សនឹងត្រូវបានណែនាំឱ្យពិភាក្សាអំពីរឿងនេះជាបន្ទាន់ ជាមួយឪពុកម្តាយ/អាណាព្យាបាល ហើយស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។ សិស្សក៏នឹងទទួលបានព័ត៌មានលម្អិតផងដែរ ដើម្បីទាក់ទងជាមួយសេវាកម្មបញ្ជូនបន្តសុខភាពដទៃទៀតដែលនឹងផ្តល់ដំបូន្មាន ការគាំទ្រ និងការណែនាំ។

## សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំកើតរោគហឺត ហើយប្រើថ្នាំ cortisone ‘ខទីហ្សូន’ ឬ prednisone ‘ប្រឹននីហ្សូន’ ដោយប្រើ “បំពង់ហឺត” (puffer)?

វ៉ាក់សាំងបង្ការជំងឺមេនីញហ្គោខូខល ACWY អាចផ្តល់ឱ្យអ្នកណាម្នាក់ដែលកើតរោគហឺតបានដោយសុវត្ថិភាព ដោយមិនគិតអំពីថ្នាំពេទ្យណាមួយដែលគេកំពុងប្រើប្រាស់ឡើយ។

## សំណួរ. តើខ្ញុំត្រូវធ្វើដូចម្ដេច ប្រសិនបើកូនរបស់ខ្ញុំខកខានការចាក់វ៉ាក់សាំងដោយសារមានជំងឺ ឬអវត្តមាននៅចំថ្ងៃគិលានុបដ្ឋាកអញ្ជើញមក?

រាល់ការខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឡើង ដើម្បីចាក់វ៉ាក់សាំងកូនរបស់អ្នកនៅគ្លីនិកសាលាជាបន្តបន្ទាប់ ក្នុងអំឡុងឆ្នាំសិក្សាថ្នាក់ទី10។ កន្លែងណាដែលមិនអាចទៅបាន អ្នកនឹងត្រូវបានណែនាំអំពីការរៀបចំចាក់វ៉ាក់សាំងដើម្បីតាមឱ្យទាន់។ ម៉្យាងវិញទៀត វ៉ាក់សាំងចាក់បន្ថែមដោយឥតគិតថ្លៃគឺអាចរកបានតាមរយៈ GP ក្នុងតំបន់របស់អ្នក និងឱសថស្ថាន។

## សំណួរ. តើខ្ញុំអាចចូលប្រើកំណត់ត្រានៃការចាក់វ៉ាក់សាំងដោយរបៀបណា?

ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក។

ឪពុកម្ដាយអាចស្នើសុំច្បាប់ចម្លងនៃសេចក្ដីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR របស់កូនពួកគេនៅពេលណាមួយ រហូតដល់កូនរបស់ពួកគេមានអាយុ១៤ឆ្នាំ ហើយសិស្សដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ អាចស្នើសុំសេចក្ដីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគដោយខ្លួនឯងដូចខាងក្រោម៖

- ដោយប្រើគណនី Medicare តាមអនឡាញ តាមរយៈ myGov my.gov.au/
- ដោយប្រើកម្មវិធី Medicare Express Plus App servicesaustralia.gov.au/express-plus-mobile-apps
- ទូរសព្ទទៅបណ្ដាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ 1800 653 809.

## សំណួរ. តើមានអ្វីកើតឡើងដល់ព័ត៌មានរបស់កូនខ្ញុំ?

ព័ត៌មានដែលអ្នកផ្ដល់នៅលើបែបបទយល់ព្រម នឹងត្រូវបានរក្សាទុកជាសម្ងាត់យ៉ាងម៉ឺងម៉ាត់ និងជាកិច្ចការពារភាពឯកជនដែលមានចែងនៅក្នុងច្បាប់រដ្ឋ NSW និងសហព័ន្ធ (សូមអានសេចក្ដីថ្លែងអំពីឯកជនភាពដែលភ្ជាប់មកជាមួយ)។ ព័ត៌មាននេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគរបស់ NSW Health រួចមកនឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក ហើយមើលឃើញនៅលើ MyGov។

## សំណួរ. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅកន្លែងណា អំពីការចាក់វ៉ាក់សាំងនៅសាលារៀន?

ព័ត៌មានបន្ថែមអាចទទួលយកបាន៖

- ដោយចូលមើលគេហទំព័រ NSW Health នៅត្រង់គេហទំព័រ www.health.nsw.gov.au/schoolvaccination
- ដោយទាក់ទងអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055

ដើម្បីផ្តល់ការយល់ព្រមតាមអនឡាញ សូមចូលទៅកាន់គេហទំព័រ https://engage.health.nsw.gov.au/engage

**ព័ត៌មានបន្ថែម៖**

NSW GOVERNMENT

240750-2-13

គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ សូមបំពេញទម្រង់ជាភាសាអង់គ្លេស

Khmer

# ការយល់ព្រមដើម្បីទទួលការចាក់វ៉ាក់សាំង មេនីញហ្គោខូខល ACWY

NSW GOVERNMENT

ត្រូវបំពេញដោយឪពុក ឬម្តាយ/អាណាព្យាបាល។ សូមសរសេរជា**អក្សរពុម្ព**ដោយប្រើប៊ិចពណ៌**ខ្មៅ** ឬ**ខៀវ**។

## 1. ព័ត៌មានលម្អិតរបស់សិស្ស (ព័ត៌មានលម្អិតទាំងនេះត្រូវតែផ្ទៀងផ្ទាត់ទៅនឹងព័ត៌មានលម្អិតដែលបង្ហាញនៅលើប័ណ្ណ Medicare)

នាមត្រកូល

នាមខ្លួន

អាសយដ្ឋានអូស្ត្រាលីរបស់កុមារ (ឧទាហរណ៍ 5 SMITH LANE)

តំបន់

លេខកូដប្រៃសណីយ៍

ថ្ងៃខែឆ្នាំកំណើត __ / __ / 2 0 __

ភេទ ☐ ប ☐ ស្រ ☐ មិនជាក់លាក់/អន្តរភេទ/មិនបានបញ្ជាក់

ថ្នាក់រៀន

ឈ្មោះសាលារៀន

លេខមេឌីឃែរ

☐ លេខនៅក្បែរឈ្មោះកូនរបស់អ្នកនៅលើប័ណ្ណមេឌីឃែរ

## 2. ស្ថានភាពជាជនជាតិដើម

☐ ទេ ☐ បាទ/ចាស ជនជាតិដើម ☐ បាទ/ចាស អ្នកកោះ Torres Strait ☐ បាទ/ចាស ជនជាតិដើម និងអ្នកកោះ Torres Strait

## 3. ព័ត៌មានលម្អិតរបស់អ្នក – ឪពុក ឬម្តាយ/អាណាព្យាបាល

ខ្ញុំបានអាន ហើយយល់ដឹងអំពីព័ត៌មានដែលបានផ្តល់ ទាក់ទិននឹងគុណប្រយោជន៍ និងផលប៉ះពាល់បន្ទាប់បន្សំដែលអាចកើតមានពីវ៉ាក់សាំង មេនីញហ្គោខូខល ACWY។

តាមរយៈនេះ ខ្ញុំសូមផ្តល់ការយល់ព្រមឱ្យកូនរបស់ខ្ញុំ ដូចមានឈ្មោះខាងលើ ដើម្បីទទួលការចាក់តែមួយដូសនៃវ៉ាក់សាំង មេនីញហ្គោខូខល ACWY។

ខ្ញុំសូមប្រកាស តាមដែលខ្ញុំដឹងជាក់ច្បាស់ថាកូនរបស់ខ្ញុំ៖

1. ពុំដែលមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) បន្ទាប់ពីចាក់វ៉ាក់សាំងណាមួយឡើយ។
2. មិនមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) ចំពោះសមាសធាតុវ៉ាក់សាំងណាមួយដែលមានរាយក្នុងសន្លឹកព័ត៌មានសម្រាប់ឪពុកម្តាយដែលដាក់ភ្ជាប់មកជាមួយទេ។
3. មិនមានផ្ទៃពោះទេ។

ឈ្មោះឪពុក ឬម្តាយ/អាណាព្យាបាល (ឧទាហរណ៍ JOHN SMITH)

លេខទូរសព្ទចល័ត

លេខទូរសព្ទផ្សេងទៀតដែលល្អជាងគេ (មានរួមទាំងលេខតំបន់ ឧទាហរណ៍ 02)

អាសយដ្ឋានអ៊ីមែល

ហត្ថលេខាឪពុក ឬម្តាយ/អាណាព្យាបាល

✕

ថ្ងៃទី __ / __ / 2 0 __

# កំណត់ត្រានៃការចាក់វ៉ាក់សាំង មេនីញហ្គោខូខល ACWY

ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល។
(ព័ត៌មានលម្អិតទាំងនេះត្រូវតែផ្គូផ្គងទៅនឹងព័ត៌មានលម្អិតដែលបង្ហាញនៅលើប័ណ្ណ Medicare)

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

## សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

✕

ថ្ងៃទី __ __ / __ __ / 2 0 __ __

**កំណត់ចំណាំរបស់គិលានុបដ្ឋាក**

មូលហេតុមិនបានចាក់វ៉ាក់សាំង

- ☐ អវត្តមាន
- ☐ បដិសេធ
- ☐ មិនស្រួលខ្លួន
- ☐ ពុំមានហត្ថលេខា
- ☐ ដកចេញការយល់ព្រម
- ☐ ផ្សេងទៀត

# **ឪពុក ឬម្ដាយ/អាណាព្យាបាល** កំណត់ត្រានៃការចាក់វ៉ាក់សាំង មេនីញហ្គោខូខល ACWY

## កំណត់ត្រានៃការចាក់វ៉ាក់សាំង មេនីញហ្គោខូខល ACWY

ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល។

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

## សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

✕

ថ្ងៃទី __ __ / __ __ / __ __ __ __

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្ដល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT